# គោលនយោបាយទំនុកបម្រុងផ្នែកហិរញ្ញវត្ថុ

## សេចក្តីសង្ខេបព័ត៌មាន

## កម្មវិធីទំនុកបម្រុងផ្នែកហិរញ្ញវត្ថុដែលយើងផ្តល់ជូន

Tufts Medicine ពិតជាមានមោទនភាពក្នុងការផ្តល់នូវសេវាថែទាំវេជ្ជសាស្ត្រដ៏ប្រសើរសម្រាប់អ្នកជំងឺគ្រប់រូប។ Tufts Medicine ក៏ផ្តល់នូវកម្មវិធីទំនុកបម្រុងផ្នែកហិរញ្ញវត្ថុជូនដល់អ្នកជំងឺដែលមិនមានលទ្ធភាពបង់ថ្លៃសម្រាប់សេវាសង្គ្រោះបន្ទាន់ និងសេវាថែទាំវេជ្ជសាស្ត្រចាំបាច់នានា។

### តើខ្ញុំបំពេញលក្ខខ័ណ្ឌគ្រប់គ្រាន់ឬទេ?

យើងលើកទឹកចិត្តឱ្យអ្នកជំងឺបង់ប្រាក់ថ្លៃសេវាកម្មនានា របស់អង្គភាព Tufts Medicine ប្រសិនបើពួកគេមានលទ្ធភាព។ ទោះជាយ៉ាងណាក៏ដោយ ដើម្បីទទួលបានការទំនុកបម្រុងផ្នែកហិរញ្ញវត្ថុ អ្នកត្រូវបំពេញលក្ខខ័ណ្ឌមួយចំនួន ដែលអាស្រ័យលើកត្តាជាច្រើន រួមមាន៖ ការធានារ៉ាប់រង ប្រាក់ចំណូល (គោលការណ៍ណែនាំកម្រិតភាពក្រីក្ររបស់រដ្ឋាភិបាលសហព័ន្ធដែលប្រើដើម្បីកំណត់នូវទំហំហិរញ្ញវត្ថុដែលអាចផ្តល់ជូន) ទំហំគ្រួសារ ទ្រព្យសម្បត្តិ សិទ្ធិស្នាក់នៅ និងវិក្កយបត្រវេជ្ជសាស្ត្រផ្សេងទៀត .

- យើងផ្តល់ការទំនុកបម្រុងហិរញ្ញវត្ថុចំពោះអ្នកជំងឺដែលមិនមានធានារ៉ាប់រង និងមានធានារ៉ាប់រងតែមិនគ្រប់គ្រាន់។ យើងផ្តល់ការទំនុកបម្រុងផ្នែកហិរញ្ញវត្ថុទាំងស្រុង ឬដោយចំណែកណាមួយ ដោយផ្អែកលើលទ្ធភាពបង់ប្រាក់របស់អ្នកជំងឺ។
- អ្នកជំងឺត្រូវតែបំពេញគ្រប់លក្ខខ័ណ្ឌក្នុងដំណើរការដាក់ពាក្យសុំ រួមទាំងការដាក់លិខិតប្រកាសពន្ធ របាយការណ៍ធនាគារ និងលិខិតបញ្ជាក់ការបង់ប្រាក់ ហើយត្រូវអនុវត្តរាល់ដំណើរការដាក់ពាក្យសុំសម្រាប់ប្រភពជំនួយដែលមានទាំងអស់

រួមទាំងMedicaid ឬកម្មវិធីរបស់រដ្ឋាភិបាលសហព័ន្ធផ្សេងទៀត។

## តើខ្ញុំត្រូវដាក់ពាក្យដោយរបៀបណា?

ប្រសិនបើអ្នកពុំមានលទ្ធភាពបង់ប្រាក់ សូមចូលទៅកាន់គេហទំព័ររបស់យើងនៅ tuftsmedicalcenter.org/financialassistance ដើម្បីទទួលបានព័ត៌មាន ក៏ដូចជាទាញយកឯកសារ និងព្រីនថ៍ព័ត៌មាន ដើម្បីស្វែងយល់បន្ថែមអំពីកម្មវិធីទំនុកបម្រុងផ្នែកហិរញ្ញវត្ថុដែលមានផ្តល់ជូន។ គោលការណ៍ និងកម្មវិធីទំនុកបម្រុងផ្នែកហិរញ្ញវត្ថុ Tufts Medicine អាចរកបានដោយឥតគិតថ្លៃ នៅលើគេហទំព័រ និងតាមរយៈការសម្របសម្រួលហិរញ្ញវត្ថុ។ អ្នកអាចស្នើសុំឱ្យយើងផ្ញើព័ត៌មានទាំងអស់នេះតាមរយៈអ៊ីម៉ែលទៅកាន់អ្នកបានផងដែរ។

## លក្ខខ័ណ្ឌលើកលែង

គោលការណ៍នេះអនុវត្តតែចំពោះសេវាកម្មវេជ្ជសាស្ត្រចាំបាច់ ដែលផ្តល់ជូនដោយអង្គភាព Tufts Medicine តែប៉ុណ្ណោះ។ គោលការណ៍នេះមិនអនុវត្តចំពោះសេវាកម្មដែលផ្តល់ដោយគ្រូពេទ្យឯករាជ្យ ឬអ្នកជំនាញវេជ្ជសាស្ត្រ ដែលបម្រើការក្រៅអង្គភាព Tufts Medicine ឡើយ។ គោលការណ៍នេះក៏រួមបញ្ចូលទាំងគ្រូពេទ្យឯកទេសខាងថ្នាំស្ពឹក អ្នកជំនាញផ្នែកវិទ្យុសកម្ម និងគ្រូពេទ្យផ្នែករោគសាស្ត្រ។

## ផ្សេងៗ

គ្មានបុគ្គលណាដែលបំពេញលក្ខខ័ណ្ឌគ្រប់គ្រាន់ដើម្បីទទួលបានការទំនុកបម្រុងផ្នែកហិរញ្ញវត្ថុ ហើយត្រូវគិតប្រាក់បន្ថែមលើសពីទំហំទឹកប្រាក់គិតថ្លៃជាទូទៅ (AGB) សម្រាប់សេវាសង្គ្រោះបន្ទាន់ ឬសេវាថែទាំវេជ្ជសាស្ត្រចាំបាច់ផ្សេងទៀតឡើយ។

ការថែទាំចាំបាច់។

**សម្រាប់អ្នកមិនចេះភាសាអង់គ្លេស**

財務補助文件亦有中文翻譯版。

Os documentos de Assistência Financeira estão disponíveis no idioma português.

Документы о финансовой помощи имеются на русском языке.

Hay traducciones de los documentos de Asistencia Financiera disponibles en español.

Cac bản dịch thuật tai liệu về Hỗ trợ Tai chinh co sẵn bằng Tiếng Việt.

## អ្នកអាចទាក់ទងនាយកដ្ឋានសម្របសម្រួលហិរញ្ញវត្ថុទាំងបី តាមខ្សែទូរស័ព្ទ ឬដោយផ្ទាល់នៅ៖

- មជ្ឈមណ្ឌលវេជ្ជសាស្ត្រ Tufts

  Biewend Building, ជាន់ទីមួយ, ផ្លូវ 260 Tremont, Boston, MA 02111

  T 978.937.6700

- មជ្ឈមណ្ឌលវេជ្ជសាស្ត្រ Tufts

  អគារ Proger, ជាន់ទីមួយ, ផ្លូវ 800 Washington, Boston, MA 02111

  T 978.937.6700

- មន្ទីរពេទ្យទូទៅ Lowell

  អគារ Dahod, ជាន់ផ្ទាល់ដី, វិថី 295 Varnum, Lowell, MA 01854

  T 978-937-6700

- មន្ទីរពេទ្យទូទៅ Lowell General Saints Campus

  ជាន់ផ្ទាល់ដី, 1 Hospital Drive, Lowell, MA 01852

  T 978-937-6700

- មន្ទីរពេទ្យ Melrose Wakefield

  ផ្លូវ Porter, ជាន់ទីមួយ, ផ្លូវ 585 Lebanon, Melrose, MA 02176

  T 978-937-6700

- មន្ទីរពេទ្យ Lawrence Memorial

  Ground Floor near Urgent Care, 170 Governors Avenue, Medford, MA 02155

  T 978-937-6700

TuftsMedicine